## ការគ្រួតត្រាសេដ្ឋកិច្ចដោយសំងាត់របស់ក្រុមគ្រួសារកាន់អំណាចនៅកម្ពុជាបង្កការខាតបង់យ៉ាងច្រើន ដីវភាពរស់នៅដល់ប្រជាជននិងហានិភ័យធំធេងសម្រាប់វិនិយោគិនបរទេស

ប្រតិបត្តិការស៊ើបអង្កេតដ៏ធំមួយរបស់ អង្គការ Global Witness បានលាតត្រដាងអំពីរបៀបដែលក្រុមគ្រួសារកាន់អំណាចនៅប្រទេសកម្ពុជា កំពុងគ្រួតត្រាសេដ្ឋកិច្ចរបស់ប្រទេសនេះ និងប្រមូលលាភសការៈជាច្រើនសម្រាប់ខ្លួនឯង ដែលជាហេតុធ្វើឲ្យមានផលប៉ះពាល់ខ្លាំងដល់ប្រជាពលរដ្ឋកម្ពុជា។ របាយការណ៍ដែលមានឈ្មោះថា*Hostile Takeover* បានលាតត្រដាងអំពីបណ្តាញដ៏ធំមហិមានៃកិច្ចព្រមព្រៀងសម្ងាត់និងអំពើពុករលួយដែលជួយគាំទ្ររបបដឹកនាំផ្តាច់ការរយៈពេល 30 ឆ្នាំ ដែលមានការធ្វើឃាត ការធ្វើទារុណកម្មនិងការចាប់ដាក់ពន្ធនាគាលើគូរប្រជែងនយោបាយរបស់លោក ហ៊ុនសែន។(1)

ដោយប្រើទិន្នន័យសិទ្ធិកាន់កាប់ក្រុមហ៊ុនដែលរដ្ឋាភិបាលតែងតែរិតបន្តឹងមិនឲ្យគេយកបាននោះ អង្គការ Global Witnessបានបង្ហាញថា តើសមាជិកគ្រួសារត្រកូល ហ៊ុន ធ្វើកាន់កាប់ពេញលេញ ឬកាន់កាប់ដោយផ្នែកក្នុងក្រុមហ៊ុនជាច្រើន ដែលដើមទុនចុះបញ្ជីជាង200 លានដុល្លារសហរដ្ឋអាមេរិក។ក្រុមហ៊ុនទាំងនេះគ្រួតត្រាវិស័យសំខាន់ភាគច្រើននៃសេដ្ឋកិច្ច ដោយមានសម្ព័ន្ធភាពជាមួយទៅនឹងក្រុមហ៊ុនម៉ាកល្បីៗលំដាប់អន្តរជាតិដូចជា Apple, Nokia, Visa, Unilever, Procter & Gamble, Nestlé, Durex និង Honda ដើម។

នេះគ្រាន់តែជាផ្នែកមួយនៃចំនួនទឹកប្រាក់ពិតប្រាកដនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មគ្រួសារត្រកូល ហ៊ុន ប៉ុណ្ណោះ។ ពួកគេត្រូវបានគេជឿថា ទទួលបានផលប្រយោជន៍ពាណិជ្ជកម្មពីអ្នកដែលឈរឈ្មោះជំនួសពួកគេ និងនៅក្នុងក្រុមហ៊ុនដែលមានតែឈ្មោះ។ គ្រួសារត្រកូល ហ៊ុន ក៏រាប់បញ្ចូលទាំងសមាជិក ដែលធ្លាប់ជាប់ពាក់ព័ន្ធនឹងសកម្មភាពរត់ពន្ធអាវុធដែលមានតម្លៃ 1 ពាន់លានដុល្លារអាមេរិក បាញ់បោះ បុកស្លាប់ហើយរត់ និងសកម្មភាពទន្ទ្រានយកដីដែលបណ្តាលឲ្យប្រជាជនជាច្រើនគ្រួសារត្រូវបាត់បង់លំនៅដ្ឋាន និងរស់នៅក្នុងភាពទាល់ក្រនៅតំបន់ជនបទក្រីក្រនៃប្រទេសកម្ពុជា។ របាយការណ៍ត្រូវបានចេញផ្សាយ បន្ទាប់ពីមានការធ្វើយុទ្ធនាការតវ៉ា ថ្ងៃច័ន្ទពណ៌ខ្មៅ បានរយៈពេលពីខែ ក្នុងគោលបំណងប្រតិបត្តិទៅនឹងប្រតិបត្តិការបង្ក្រាបរបស់អាជ្ញាធរលើអ្នករិះគន់ពួកគេ ដោយផ្ទង់គោលដៅចំពោះគណបក្សនយោបាយប្រឆាំង សកម្មជនសហគមន៍និងក្រុមសង្គមស៊ីវិល។

លោក Patrick Alley សហស្ថាបនិកនៃអង្គការ Global Witness បានមានប្រសាសន៍ថា "គំហើញទាំងនេះបានបង្ហាញពីផលវិបាកនៃការប្រតិបត្តិគំរូនៃការដឹកនាំបែបផ្តាច់ការរបស់ លោក

ហ៊ុនសែន។ គ្រួសាររបស់គាត់ត្រួតត្រាសេដ្ឋកិច្ចរបស់ ប្រទេសកម្ពុជា ហេតុដូចនេះពលរដ្ឋក្រុងភ្នំពេញហាក់ដូចជាមិនអាចជៀសផុតពីការរួមចំណែករកលុយចូលហោប៉ៅរបស់អ្នកជិះជាន់គៀបសង្កត់របស់ពួកគេជាច្រើនដងក្នុងមួយថ្ងៃឡើយ។ ចំណែកឯវិនិយោគិនបរទេសវិញ អាចនិងពុំគួរចូលរួមគាំទ្ររបបដែលដែលសម្លាប់ បំភិតបំភ័យ ឬឃុំខ្លួនអ្នករិះគន់របបនេះទេ″។

របាយការណ៍ *Hostile Takeover*ក៏បានបង្ហាញថា គ្រួសាររបស់លោកនាយករដ្ឋមន្ត្រីរូបនេះ ដើរតួរយ៉ាងសំខាន់ក្នុងការជួយរក្សាភាពស្ថិតស្ថេរយូរអង្វែងនៃអាជីពនយោបាយរបស់គាត់។ ពួកគេកាន់តំណែងសំខាន់ៗក្នុងកិច្ចការ នយោបាយ កងកម្លាំងយោធា នគរបាល ប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នមនុស្សធម៌ ដែលស៊ុទ្ធតែជាផ្នែកដែលជួយគាំទ្រគណបក្សរបស់លោកហ៊ុនសែន តាមរយៈការឃោសនា ការបរិចាកនិយោបាយ ឬក៏ការប្រើកំលាំងប្រៃផ្សៃជាដើម។

ក្រុមហ៊ុនក្នុងស្រុកមួយចំនួនដែលពាក់ព័ន្ធនឹងពួកគេ ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានជាច្រើនរួមមាន ការលួចយកដីធ្លី និងធនធានធម្មជាតិ អំពើហិង្សានិងការបំភិតបំភ័យលើប្រជាជនក្នុងមូលដ្ឋាន និងការបំផ្លិចបំផ្លាញបរិស្ថាន។

ក្នុងចំណោមឧទាហរណ៍ជាក់ស្តែងបំផុតទាំងឡាយ ក្រុមហ៊ុនកសិកម្មមួយត្រូវបានចោទប្រកាន់ថាបានប្រើវិធីលួចដុតផ្ទះ និងយកពស់វែកទៅបណ្តេញប្រជាជនឲ្យចេញពីផ្ទះរបស់ពួកគាត់។ ករណីនេះគឺជាករណីមួយក្នុងចំណោមករណីធំៗជាច្រើនទៀតដែលត្រូវបានដាក់ពាក្យបណ្តឹងទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដោយមានមានភស្តុតាង ដែលបញ្ជាក់ថា ពួកអ្នកកាន់អំណាចគ្រប់គ្រងប្រទេសកម្ពុជាបានប្រព្រឹត្តអំពើរំលោភយកដីធ្លីយ៉ាងខ្លាំងក្លាដែលអាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំមនុស្សជាតិ។

អង្គការ Global Witnessមិនអាចរកឃើញករណី ដែល មានសមាជិកក្រុមគ្រួសាររបស់លោកហ៊ុនសែនណាមួយ ត្រូវបានកាត់ទោស ឬទទួលពិន័យ ដោយសារតែបានប្រព្រឹត្តអំពើខុសច្បាប់របស់ពួកគេឡើយ។

ចំណែកឯលោកហ៊ុនសែនវិញបានដើរបញ្ចុះបញ្ចូលវិនិយោគិនពីបរទេសយ៉ាងសកម្ម ដោយឡូងសេថា ប្រទេសកម្ពុជាគឺជាកន្លែងវិនិយោគដ៏ទាក់ទាញដោយមានច្បាប់អនុវត្តច្រើន និងថ្លៃពលកម្មថោក។ ចិនគឺជាវិនិយោគិនបរទេសផ្ទាល់ច្រើនជាងគេក្នុងប្រទេសកម្ពុជាដោយបានចូលរួមចំណែក18ភាគរ

យក្នុងឆ្នាំ2015 បន្ទាប់មកគឺអង់គ្លេសមានចំនួន៣ភាគរយ។ សហរដ្ឋអាមេរិកគឺជាដៃគូពាណិជ្ជកម្មធំបំផុតរបស់កម្ពុជា ដោយទទួលយកការនាំចេញមួយភាគបីនៃបរិមាណនាំចេញសរុបរបស់ប្រទេសកម្ពុជា ហើយមានតំលៃស្មើនឹង3 ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។

លោក Stephen Peel អតីតអ្នកគ្រប់គ្រងជាន់ខ្ពស់នៅក្នុងក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មឯកជន TPG Capital និងជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់អង្គការ Global Witness បានថ្លែងថា "អង្គការ Global Witnessបានគូររូបភាពដ៏រស់រវើកនៃអ្នកចំណេញនិងអ្នកខាតពីការវិនិយោគបរទេសនៅក្នុងប្រទេសកម្ពុជា។ ការធ្វើអាជីវកម្មជាមួយនឹងក្រុមហ៊ុនដែលជាកម្មសិទ្ធនិងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមគ្រួសាររបស់គ្រួសារគ្រប់គ្រងប្រទេសកម្ពុជា មិនត្រឹមតែបង្កើតឲ្យមានសំនួរផ្នែកសិលធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កឲ្យមានហានិភ័យផ្នែកច្បាប់ ហិរញ្ញវត្ថុ និងកេរ្តិ៍ឈ្មោះទៀតផង។ វាជាសារៈសំខាន់ខ្លាំងបំផុតដែលវិនិយោគិនក្នុងប្រទេសកម្ពុជា ត្រូវពិនិត្យដោយប្រុងប្រយ័ត្ន ដើម្បីធានាថាប្រាក់របស់ខ្លួនត្រូវបានត្រូវបានចាក់បញ្ចូលយុទ្ធនាការជិះជាន់របស់ហ៊ុនសែន"។(3)

**អនុសាសន៍គន្លឹះ**

<u>រាជរដ្ឋាភិបាលកម្ពុជា៖</u>

- ធ្វើការស៊ើបអង្កេតដោយឯករាជនិងតម្លាភាពចំពោះការចោទប្រកាន់ដែលបានលើកឡើងនៅក្នុង របាយការណ៍ *Hostile Takeover* ហើយកាត់ទោសបុគ្គលនិងបណ្តាលក្រុមហ៊ុនដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើខុសច្បាស់នៃព្រះរាជាណាចក្រកម្ពុជា។
- បញ្ចប់រាល់សកម្មភាពឃោឃៅដែលកំពុងតែកើតឡើងនៅក្នុងពេលថ្មីៗនេះរួមមាន៖
  -បញ្ចប់ការបន្តធ្វើទុក្ខបុកម្នេញដល់អ្នករិះគន់រដ្ឋាភិបាល។
  -ធានាថា ច្បាប់គាបសង្កត់ដែលកំពុងត្រូវបាន ព្រៀងនាពេលបច្ចុប្បន្ននឹងមិនត្រូវអនុម័តឡើយ ហើយច្បាប់គាបសង្កត់ប្រហាក់ប្រហែលដែលបានអនុម័តនាពេលថ្មីៗនេះបានត្រូវទុកកជានិរាករណ៍។

<u>សមាជិកគ្រួសារត្រកូល ហ៊ុនរួមទាំងលោកហ៊ុនសែនផង៖</u>

- ប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនជាសាធារណៈឲ្យបានពេញលេញ ដោយរួមបញ្ចូលទាំងទំនាកទំនងនៅក្នុងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស មិនថាទំនាក់ទំនងនោះជាផ្លូវការឬក្រៅផ្លូវការនោះទេ។

<u>ក្រុមហ៊ុនវិនិយោគជាមួយ/កំពុងពិចារណាវិនិយោគក្នុងប្រទេសកម្ពុជា៖</u>

- សិក្សាស្រាវជ្រាវ និងវិភាគ
  ឲ្យបានគ្រប់ជ្រុងជ្រោយលើការវិនិយោគរបស់ខ្លួនដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើមានទំនាក់ទំនងអ្វីខ្លួនជាមួយនឹងពាណិជ្ជកម្មឬក៏អ្នកមានអំណាច នយោបាយកំពូលៗ(រួមបញ្ចូលទាំងអ្នកពាក់ព័ន្ធនយោបាយទាំងអស់) ដែលមានប្រវត្តិជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ថា បានប្រព្រឹត្តិអំពើពុករលួយ ឬសមាជិកគ្រួសាររបស់ពួកគេ តាមរយៈភាពជាដៃគូផ្លូវការ សិទ្ធិ តាមរយៈសង្វាក់ផ្គត់ផ្គង់កិច្ចព្រមព្រៀងចែកចាយផ្តាច់មុខ ឬសូម្បីតែការទំនាក់ទំនងធូររលុងជាមួយអតិថិជន។

សម្រាប់កិច្ចសម្ភាសន៍ (ជាភាសាអង់គ្លេស) ព័ត៌មានសង្ខេប និងព័ត៌មានផ្សេងៗទៀត សូមទាក់ទង៖

Patrick Alley +44 (0)20 7492 5887 palley@globalwitness.org
Alice Harrison +44 (0)7841 338792 aharrison@globalwitness.org

កំណត់សម្គាល់សម្រាប់អ្នកនិពន្ធ៖

(1) អង្គការ Global Witness បានសរសេរលិខិតផ្ញើជូនលោកនាយករដ្ឋមន្ត្រីហ៊ុនសែនសមាជិកនៃក្រុមគ្រួសាររបស់គាត់ 26រូបនិង 42 រូបក្រុមហ៊ុនក្នុងចំណោម ក្រុមហ៊ុនដែលពួកគេត្រូវមានទំនាក់ទំនងជាមួយ ដើម្បីផ្តល់ជូននូវឱកាសដល់ពួកគាត់ សម្រាប់ឆ្លើយតបទៅនឹងការចោទប្រកាន់របស់យើង។ មានក្រុមហ៊ុនចំនួនប្រាំមួយបានឆ្លើយតប ក៏ដូចជាលោកសុខពុទ្ធីវុធដែលជាកូនប្រសាររបស់លោកហ៊ុនសែន។ ចម្លើយតបរបស់ពួកគេក៏ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ *Hostile Takeover* ផងដែរ។

(1) ទិន្នន័យទាក់ទងនឹងការចុះបញ្ជីក្រុមហ៊ុនដែលបានផ្តល់ឲ្យរបាយការណ៍នេះត្រូវបានដកស្រង់ពីប្រភពដើម គឺនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មដែលរដ្ឋាភិបាលបានរឹតបន្តឹងឲ្យចូលស្វែងរក។ អង្គការGlobal Witness បានប្រើប្រាស់ទិន្នន័យទាំងនេះដើម្បីបង្កើតគេហទំព័រ មូលដ្ឋានទិន្នន័យក្រុមហ៊ុន*Cambodia Corporates*ជាមូលដ្ឋានទិន្នន័យមួយដែលអាចចូលមើលជាសាធារណៈរុករកដោយពេញលេញនិងមានសុវត្ថិភាពហើយអង្គការនេះនឹងដាក់ឲ្យប្រើប្រាស់ក្នុងពេលជាមួយគ្នានឹងរបាយការណ៍នេះផងដែរ។

មូលដ្ឋានទិន្នន័យនេះនឹងផ្តល់លទ្ធភាពដល់វិនិយោគិនអ្នកសារព័ត៌មាន និងពលរដ្ឋទូទៅក្នុងការស្វែងរកអ្នកដែលជាម្ចាស់អ្នកគ្រប់គ្រង ឬអ្នកមានភាគហ៊ុនធំនៅក្នុងក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា៖www.cambodiacorporates.globalwitness.org។

)2សេចក្តីយោងសម្រាប់សេចក្តីថ្លែងការណ៍ (ដែលលើកឡើងនៅក្នុងសេចក្តីប្រកាសព័ត៌មាននេះ សូមមើលរបាយការណ៍លម្អិត *Hostile Takeover*។ *អណាចក្រសារជីវកម្មនៃគ្រួសារកាន់អំណាចនៅក្នុងប្រទេសកម្ពុជា*ដែលមាននៅលើគេហទំព័រអង្គការ Global Witness។